**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**លេខ** ២៥៥ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១១

# ប្រកាស
# ស្តីពី
# បែបបទនៃការពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និង ការបាត់បែងប្រាក់ចំណូល បានមកពីការផាកពិន័យរថយន្តដែលបិទឬបាំងកញ្ចក់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០ ស្តីពីការប្រើប្រាស់រថយន្តដែលបិទ ឬបាំងកញ្ចក់
- បានឃើញអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- យោងតាមសំណូមពរការងារចាំបាច់

## <u>សម្រេច</u>

**ប្រការ ១ .-**

អនុវត្តតាមមាត្រា ៩ នៃអនុក្រឹត្យស្តីពី ការប្រើប្រាស់រថយន្តដែលបិទ ឬបាំងកញ្ចក់ ការផាកពិន័យអន្តរការណ៍ចំពោះរថយន្តកញ្ចក់ពណ៌ ឬដាក់របាំងរាំងនន

បាំងកញ្ចក់ដែលមើលពីក្រៅទៅក្នុងមិនឃើញ ដែលធ្វើចរាចរណ៍នៅលើផ្លូវសាធារណៈ ជាសមត្ថកិច្ចរបស់នគរបាលចរាចរណ៍ផ្លូវគោក ។

**ប្រការ ២ .-**

ប័ណ្ណផាកពិន័យអន្តរការណ៍ បទល្មើសចរាចរណ៍ផ្លូវគោក ត្រូវបានយកមកប្រើប្រាស់ជាបណ្ដោះអាសន្ន សម្រាប់ការផាកពិន័យអន្តរការណ៍ ចំពោះរថយន្តកញ្ចក់ពណ៌ ឬដាក់របាំងរាំងនន បាំងកញ្ចក់ដែលមើលពីក្រៅទៅក្នុងមិនឃើញ ។

ប័ណ្ណផាកពិន័យណាផ្សេងពីប័ណ្ណដែលបានកំណត់ក្នុងប្រកាសនេះ ត្រូវហាមឃាត់ ។

**ប្រការ ៣ .-**

បែបបទ និងចំនួនទឹកប្រាក់នៃការផាកពិន័យអន្តរការណ៍ ចំពោះរថយន្តកញ្ចក់ពណ៌ ឬដាក់របាំងរាំងននបាំងកញ្ចក់ និងនាំចូលរថយន្តកញ្ចក់ពណ៌ ដោយគ្មានការអនុញ្ញាត ត្រូវអនុវត្តតាមមាត្រា ៧ នៃអនុក្រឹត្យស្ដីពី ការប្រើប្រាស់រថយន្តដែលបិទ ឬបាំងកញ្ចក់ ។

**ប្រការ ៤ .-**

ការប្រមូល ការបែងចែកប្រាក់ឧបត្ថម្ភ និងការបង់ចូលថវិការដ្ឋនូវចំណូលពីការផាកពិន័យអន្តរការណ៍លើករណីរថយន្តដែលបិទ ឬបាំងកញ្ចក់ ដែលមើលពីក្រៅទៅក្នុងមិនឃើញ ដោយគ្មានការអនុញ្ញាត ត្រូវអនុវត្តតាមប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ៣៩០ សហវ.ប្រក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១០ ស្ដីពីការកែសម្រួល ការប្រមូល ការបែងចែកប្រាក់ឧបត្ថម្ភ និងការបង់ចូលថវិការដ្ឋ នូវចំណូលពីការផាកពិន័យអន្តរការណ៍ លើករណីល្មើសច្បាប់ចរាចរណ៍ផ្លូវគោក ។

**ប្រការ ៥ .-**

ជនណានាំចូលរថយន្តកញ្ចក់ពណ៌ ដែលមើលពីក្រៅទៅក្នុងមិនឃើញផ្ទុយនឹងបទប្បញ្ញត្តិ នៃអនុក្រឹត្យស្ដីពី ការប្រើប្រាស់រថយន្ត ដែលបិទ ឬបាំងកញ្ចក់ ដូចយោងខាងលើ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២.០០០.០០០ (ពីរលាន)រៀល ហើយត្រូវធ្វើការកែតម្រូវ ។ ក្នុងករណីមិនបានបង់ប្រាក់ពិន័យភ្លាម ត្រូវពិន័យបន្ថែមចំនួន ២០.០០០ (ពីរម៉ឺន) រៀល ក្នុងមួយថ្ងៃ លើប្រាក់ពិន័យមូលដ្ឋាន ។

ក្នុងករណីមិនបង់ប្រាក់ពិន័យលើសពី ៣០ (សាមសិប) ថ្ងៃ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

ការផាកពិន័យអន្តរការណ៍ លើការនាំចូលយានយន្តកញ្ចក់ពណ៌ដែលមើលពីក្រៅទៅក្នុងមិនឃើញ ជាសមត្ថកិច្ចរបស់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវសរសេរនៅក្នុងបង្កាន់ដៃទទួលប្រាក់ គរ . IV ដែលត្រូវបង់ចូលថវិកាជាតិ ក្នុងអនុគណនី 7106 ស្តីពីពិន័យផ្សេងៗលើការនាំចូល និងតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

**ប្រការ ៦ .-**

អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានកស្តុការ និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នាយកដ្ឋានសណ្តាប់ធ្នាប់ ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត អធិការដ្ឋាននគរបាលក្រុង-ស្រុក-ខណ្ឌ និងអង្គភាពពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **ឧបនាយករដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** |
| | គាត ឈន់ |